កម្មវិធីរង្វាន់អ្នកសន្សំសំចៃថាមពល

# មកស្គាល់ថាមពលរបស់អ្នក



*ជួយរដ្ឋកាលីហ្វ័រញ៉ាការពារការដាច់ចរន្តអគ្គិសនីនៅរដូវក្ដៅនេះ។ អ្នកចូលរួមទទួលបានប្រាក់កម្រៃសម្រាប់ការកាត់បន្ថយការប្រើប្រាស់ថាមពលក្នុងអំឡុងពេលនៃតម្រូវការខ្ពស់ និងគ្រាមានអាសន្ន ដោយមានគោលដៅជៀសវាងការដាច់ចរន្តអគ្គិសនីឆ្លាស់គ្នា។ ការចូលរួមគឺជាការស្ម័គ្រចិត្ត ហើយមិនមានការពិន័យចំពោះការមិនបានកាត់បន្ថយការប្រើថាមពលនោះទេ។*

## សេចក្តីផ្តើមនៃកម្មវិធី

កម្មវិធីរង្វាន់អ្នកសន្សំសំចៃថាមពលបង់ប្រាក់ជូនអតិថិជនលំនៅដ្ឋាន SDG&E® ដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពលសរុបរបស់ពួកគេដោយស្ម័គ្រចិត្ត នៅពេលដែលមានតម្រូវការខ្ពស់បំផុត។

## អត្ថប្រយោជន៍សម្រាប់អ្នក និងផ្ទះរបស់អ្នក

អ្នកចូលរួមនៅក្នុងកម្មវិធីរង្វាន់អ្នកសន្សំសំចៃថាមពលនឹងទទួលបានឥណទានវិក្កយបត្រចំនួន $2.00 ក្នុងមួយគីឡូវ៉ាត់ម៉ោង សម្រាប់ការកាត់បន្ថយការប្រើប្រាស់ថាមពលអំឡុងពេល Flex Alert (ការជូនដំណឹង Flex) ឬគ្រាមានអាសន្ននៃបណ្តាញទូទាំងរដ្ឋផ្សេងៗទៀត។

## តើអ្នកណាមានសិទ្ធិចូលរួម?

រាល់អតិថិជនអគ្គិសនីលំនៅដ្ឋានរបស់ SDG&E ដែលមានកុងទ័រឆ្លាតវៃទាំងអស់។ អតិថិជនលំនៅដ្ឋានមិនអាចជាអ្នកចូលរួមនៃកម្មវិធីលើកទឹកចិត្តដូចជា AC Saver, Capacity Bidding ឬកម្មវិធីភាគីទីបីរបស់ SDG&E ផ្សេងទៀតបានទេ។ សូមមើល ប្រការ និងលក្ខខណ្ឌផ្លូវការណ៍សម្រាប់ព័ត៌មានលម្អិតបន្ថែម។ អតិថិជនលំនៅដ្ឋានដែលចូលរួមជាមួយ Community Choice Aggregator (CCA) ឬ  Direct Access (DA) មានសិទ្ធិចូលរួមកម្មវិធីនេះ។

## តើកម្មវិធីនេះដំណើរការយ៉ាងដូចម្តេច?

ក្នុងអំឡុងពេលអាសន្នទាក់ទងនឹងបណ្តាញអគ្គិសនី ប្រតិបត្តិករប្រព័ន្ធឯករាជ្យរដ្ឋកាលីហ្វ័រញ៉ា (California Independent System Operator, CAISO) នឹងហៅ Flex Alert (ការជូនដំណឹង Flex) ។ នៅពេលដែលករណីនេះកើតឡើង SDG&E នឹងអំពាវនាវឱ្យមានព្រឹត្តិការណ៍កម្មវិធីរង្វាន់អ្នកសន្សំសំចៃថាមពល ហើយការជូនដំណឹងនឹងត្រូវបានផ្ញើចេញនៅមុនថ្ងៃព្រឹត្តិការណ៍នេះ។

## ទំនាក់ទំនង

សម្រាប់ព័ត៌មានលម្អិតបន្ថែម ឬដើម្បីចុះឈ្មោះក្នុងកម្មវិធីរង្វាន់អ្នកសន្សំសំចៃថាមពល សូមចូលទៅកាន់ ***sdge.com/powersaver***។

### លក្ខខណ្ឌតម្រូវរបស់កម្មវិធី

ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ឥណទានវិក្កយបត្រ សូមប្រើប្រាស់ថាមពលតិចជាងពេលវេលាធម្មតារបស់អ្នក ក្នុងអំឡុងព្រឹត្តិការណ៍រង្វាន់អ្នកសន្សំសំចៃថាមពល (Power Saver Rewards Event) ។

### ប្រាក់លើកទឹកចិត្ត

**$2.00**

ក្នុងមួយគីឡូវ៉ាត់ម៉ោង (ថាមពល)

### ពេលវេលាជូនដំណឹង

មុនថ្ងៃព្រឹត្តិការណ៍

### ការចូលរួម

អតិថិជនមិនអាចចូលរួមក្នុងកម្មវិធីលើកទឹកចិត្ត SDG&E ផ្សេងទៀត រួមទាំង AC Saver, Capacity Bidding ឬកម្មវិធីភាគីទីបីឡើយ។

### ហានិភ័យ

មិនមានការពិន័យចំពោះការមិនបានកាត់បន្ថយការប្រើប្រាស់ថាមពលរបស់អ្នកទេ។

តាមអ៊ីនធឺណិត
***sdge.com/powersaver***

ទូរសព្ទ
**(866)-291-9516**

© 2022 San Diego Gas & Electric Company ។ ពាណិជ្ជសញ្ញាគឺជាកម្មសិទ្ធិរបស់ម្ចាស់រៀងៗខ្លួន។ រក្សាសិទ្ធគ្រប់យ៉ាង។  S2250017 KHM 0622